# ដំណឹងជ្រើសរើសបុគ្គលិក

## គ្រូបង្វឹកអំណាន (Literacy Coach)

សមាគមបណ្តុះកុមារគឺជាអង្គការក្នុងស្រុកដែលបានប្រែក្លាយពីអង្គការអន្តរជាតិប៉ាតា (Partage) នៅឆ្នាំ ១៩៩៩។ បច្ចុប្បន្ននេះសមាគមបណ្តុះកុមារ បានធ្វើការក្នុងភាពជាដៃគូរជាមួយអង្គការអប់រំពិភពលោកកម្ពុជា (World Education Cambodia) ។ សមាគមបណ្តុះកុមារត្រូវការជ្រើសរើសបុគ្គលិកបន្ថែមដើម្បីបំពេញការងារក្នុងមុខតំណែងជា **គ្រូបង្វឹកអំណាន** (Literacy Coach) **ចំនួនសរុប ១ នាក់** សម្រាប់កម្មវិធីអំណាននៅថ្នាក់ដំបូង ដែលត្រូវអនុវត្តក្នុងខេត្តកំពង់ធំ។

### ទំនួលខុសត្រូវ:

- ផ្តល់ការជួយគាំទ្រដល់គ្រូបង្រៀននៅថ្នាក់ទី ១ តាមរយៈការចុះមើលការបង្រៀនរបស់គ្រូ និងផ្តល់ដំបូន្មានផ្នែកបច្ចេកទេស នៅតាមសាលារៀនគោលដៅ។
- ចុះជួយគ្រូដែលបង្រៀននៅថ្នាក់មត្តេយ្យដែលមានទីតាំងនៅក្នុងសាលារៀនបឋមសិក្សា។
- ចូលរួមទទួលការបំប៉នអំពីវិធីសាស្រ្តបច្ចេកទេសគាំទ្រដល់គ្រូបង្រៀន និងខ្លឹមសារនៃការបង្រៀន ពីក្រុមការងារបច្ចេកទេសរបស់គម្រោង ។
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល និងការប្រជុំនានា មួយចំនួនទៀតផងដែរ។

### លក្ខណៈសម្បត្តិ:

- មានសញ្ញាប័ត្រឬលិខិតបញ្ជាក់ការសិក្សាទាក់ទងនិងការបង្រៀន (នៅសាលារដ្ឋ ឬសាលាឯកជន) ឬជំនាញដែលពាក់ព័ន្ធ ឬជានិស្សិតឆ្នាំទី៤ដែលកំពុងសិក្សាផ្នែកអប់រំ
- មានបទពិសោធន៍បង្រៀនសិស្ស ជាពិសេសនៅបឋមសិក្សា។

- មានបទពិសោធន៍ក្នុងការគាំទ្រគ្រូ និង ប្រឹក្សាគរុកោសល្យកាន់តែប្រសើរ។
- អាចធ្វើដំណើរទៅសាលារៀននានាក្នុងស្រុកគោលដៅតាមផែនការដែលបានគ្រោងទុក ដោយប្រើប្រាស់ម៉ូតូផ្ទាល់ខ្លួនជាមធ្យោបាយ។
- មានបំណិនក្នុងការប្រាស្រ័យទាក់ទង។
- មានភាពស្ទាត់ជំនាញក្នុងការអាន និងសរសេរភាសាខ្មែរ។
- ចេះប្រើប្រាស់ Smart phone ឬថាប់ប្លេត (Tablet) ឬឧបករណ៍បច្ចេកវិទ្យាផ្សេងទៀត (នឹងទទួលបានការបំប៉នបន្ថែម)។

កាលបរិច្ឆេទឈប់ទទួលពាក្យៈ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០

## ការដាក់ពាក្យៈ

បេក្ខជន ឬបេក្ខនារី ដែលមានចំណាប់អារម្មណ៍សូមផ្ញើប្រវត្តិរូបសង្ខេប ឬបំពេញទម្រង់ពាក្យស្នើសុំដែលមានភ្ជាប់មកជាមួយ រួចផ្ញើមក**សមាគមបណ្ដុះកុមារ**តាមរយៈ អ៊ីម៉ែល rathida_sean@bandoskomar.org ឬ អាចផ្ញើតាមរយៈ:Telegram: ០៩៦ ៤៥០ ៦៣៥០ ឬក៏អាចយកពាក្យមកដាក់ផ្ទាល់នៅការិយាល័យសមាគមបណ្ដុះកុមារខេត្តកំពង់ធំ ដែរស្ថិតក្នុង សាលាគរុកោសល្យ អាគារ ទី១ បន្ទប់លេខ១ ភូមិអាចារ្យលាក់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។ សម្រាប់ព័ត៌មានលំអិត សូមទំនាក់ទំនងតាមរយៈទូរស័ព្ទ ០៩៦ ៤៥០ ៦៣៥០

និង ០១៧ ៨៤៨ ៧៩៧ ។